ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១២ អយក.សរណន

# សេចក្តីណែនាំ
## ស្តីពី
## ការបង្កើតរោងជាងនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ

ការអប់រំបំណិនជីវិតគឺជាមូលដ្ឋានគ្រឹះក្នុងការបណ្តុះជំនាញ និងគុណតម្លៃរបស់បុគ្គល តាមរយៈការបង្រៀន និងរៀនផ្នែកទ្រឹស្តី និងប្រតិបត្តិ ដែលតម្រូវឲ្យមានរោងជាងជាចាំបាច់សម្រាប់អនុវត្តន៍។ ដើម្បីពង្រឹង និងពង្រីកការងារប្រតិបត្តិឲ្យមានលក្ខណៈសមស្រប និងអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

១. គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ ត្រូវបង្កើតរោងជាងសម្រាប់ការបង្រៀន និងរៀនទ្រឹស្តី និងប្រតិបត្តិដោយបំពាក់នូវសម្ភារៈងាយៗ សម្រាប់ការអនុវត្តជាក់ស្តែង។

២. ចំពោះគ្រឹះស្ថានសិក្សាដែលមានលទ្ធភាពគ្រប់គ្រាន់ ត្រូវរៀបចំឲ្យមានបន្ទប់ដាច់ដោយឡែក ដូចជាបន្ទប់ផ្នែកជំនាងឈើ កសិកម្ម សិល្បៈ កុំព្យូទ័រ កាត់ដេរ ដាំស្ល ...។

៣. ចំពោះគ្រឹះស្ថានសិក្សាដែលពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ ត្រូវបង្កើតឲ្យមានរោងជាងសម្រាប់អនុវត្តសកម្មភាពប្រតិបត្តិ លើផ្នែកណាមួយនៃចំណុចទី២ខាងលើ ។

៤. គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវកៀរគរធនធានមូលដ្ឋានសហគមន៍ ដើម្បីបង្កើតរោងជាង និងដឹកនាំជំរុញឲ្យមានសកម្មភាពប្រតិបត្តិប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៥. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវជំរុញគ្រប់គ្រឹះស្ថានសិក្សាទាំងអស់ ឲ្យបង្កើតរោងជាង និងធ្វើឲ្យមានដំណើរការជានិរន្តរ៍ ដោយធ្វើការវាយតម្លៃដំណើរការសកម្មភាព និងធ្វើរបាយការណ៍មកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ) រៀងរាល់ឆមាសនៃឆ្នាំសិក្សានីមួយៗ។

ទទួលបានសេចក្តីណែនាំនេះ សូមលោកស្រី លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងនាយិកា នាយកគ្រឹះស្ថានសិក្សា ចាត់ចែងអនុវត្តឲ្យទទួលបានលទ្ធផលល្អ និងមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល**
- អង្គភាពក្រោមឱវាទទីស្តីការក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការិ. អយក. ក្រុង ស្រុក ខណ្ឌ
- គ្រឹះស្ថានសិក្សាក្រោមឱវាទ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ នា.ទត

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh